ក្រសួងកិច្ចការនារី

សេចក្តីសង្ខេបសម្រាប់គោលនយោបាយ ១០



# អាកាសធាតុ

## យេនឌ័រ និងការប្រែប្រួលអាកាសធាតុ

## ការអភិវឌ្ឍន៍បៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

## ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

២០១៤

រូបភាពគំរបមុខ

**ហេង ភាព** (៤១ឆ្នាំ) ជាកសិករនៅស្រុក អរិយ្យក្សត្រ ខេត្តកណ្ដាល ។
ពីមុន អ្នកស្រីគឺជាអ្នកត្បាញ តែដោយសារមិនសូវចំណេញ ក៏ប្ដូរមកស៊ីឈ្នួលធ្វើស្រែឱ្យគេវិញ
គ្រាន់បានកម្រៃខ្លះ ។

# ជំពូកទី ១០

# អាកាសធាតុ

## យេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

### បរិបទគោលនយោបាយ

#### យុទ្ធសាស្ត្រចតុកោណ

នៅក្នុងគោលដៅគ្រប់គ្រងបរិស្ថាន និងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ បានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗ បួន ៖

១. ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

២. ការខិតខំកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងសមត្ថភាពបន្សាំនិងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុពិសេសការអនុវត្ត «គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍បៃតង» និង «ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍន៍បៃតងឆ្នាំ ២០១៣-២០៣០»

៣. ការបន្តពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័ន ដើម្បីជំរុញការបញ្ជ្រាបប្រធានបទស្តីពីការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ ច្បាប់ និងផែនការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៤. ការបន្តដាក់ចេញនូវវិធានការនានា ដើម្បីគ្រប់គ្រងការបំពុល បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី។



ដើម្បីកាត់បន្ថយផលប៉ះពាល់លើស្ត្រី រាជរដ្ឋាភិបាល នឹងផ្តល់អាទិភាពលើ «ការកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់ដែលបណ្តាលមកពីជំងឺមិនឆ្លង-រ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈ ដែលពាក់ព័ន្ធនឹងសុវត្ថិភាពចំណីអាហារ ការប្រើប្រាស់គ្រឿងញៀនគ្រឿងស្រវឹង ថ្នាំជក់ គ្រោះថ្នាក់ចរាចរណ៍ គ្រោះមហន្តរាយ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។»

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបន្ត «លើកកម្ពស់តួនាទីស្ត្រីនិងយុវជនក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការពង្រីកកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ការបំពាក់បំប៉នជំនាញបច្ចេកទេសនិងសហគ្រិន ភាពព្រមទាំងការពង្រឹងភាពអង់អាចដល់ស្ត្រី និងយុវជន។»

▲ នៅឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាបានចេញគោលនយោបាយស្តីពីគម្រោងអភិវឌ្ឍន៍បៃតង

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨

- ជានាថាគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការ(គ្រប់គ្រង)គ្រោះមហន្តរាយ

បានឆ្លើយតបនឹងយេនឌ័រ។

- បង្កើននូវភាពបន្សុំានឹងការប្រែប្រួលអាកាសធាតុ ជាពិសេសដល់ស្ត្រី និងក្មេងស្រី។
- កាត់បន្ថយផលប៉ះពាល់ផ្នែកសុខភាពលើស្ត្រីនិងកុមារ ជាពិសេសក្នុងអំឡុងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។
- បង្កើនចំណេះដឹង ស្តីពីវិធានការកាត់បន្ថយ ដើម្បីធានានូវនិរន្តរភាពធនធានធម្មជាតិ និងការការពារបរិស្ថាន។
- កសាងសមត្ថភាពស្ថាប័នរដ្ឋ និងស្ថាប័នពាក់ព័ន្ធស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងផែនការសកម្មភាពនានា ដែលទាក់ទងនឹងបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

## ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤-២០២៣

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រនៅជនបទ ដែលក្នុងនោះភាគច្រើនជាស្ត្រី ជាក្រុមងាយរងគ្រោះបំផុតពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ ដោយសារតែពួកគាត់ពឹងផ្អែកជាខ្លាំងលើកសិកម្ម និងធនធានធម្មជាតិ។ ក្រុមនេះងាយទទួលរងគ្រោះពីជំងឺ ដោយសារធនធាន និងសមត្ថភាពបន្សុំានឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាការត្រៀមបង្ការពួកគាត់សម្រាប់ទប់ទល់នឹងហានិភ័យអាកាសធាតុ និងមុខសញ្ញាមហន្តរាយនៅមានកម្រិត ជាដើម។ ដូច្នេះចាំបាច់ត្រូវបញ្ជ្រាបយេនឌ័រទៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ រួមទាំងគោលនយោបាយច្បាប់ដែលមានស្រាប់ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីឱ្យបញ្ហាអន្តរវិស័យនេះបានទទួលការគាំទ្រពីស្ថាប័នរាជរដ្ឋាភិបាលទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិលនានា ស្ថាប័នស្រាវជ្រាវអប់រំ និងវិស័យឯកជន។ ឆ្លើយតបទៅនឹងបញ្ហានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ «ទិសដៅជាយុទ្ធសាស្ត្រទី២៖ កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ»។

# របកគំហើញ

## ការប្រែប្រួលអាកាសធាតុពិភពលោក និងផលប៉ះពាល់ដល់កម្ពុជា

មាននិយមន័យជាច្រើននៃពាក្យ«ការប្រែប្រួលអាកាសធាតុ»ដូចជាទីភ្នាក់ងារថាមពលអន្តរជាតិ (IEA)[1] កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)[2] ឬក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)[3] ជាដើម។ ក្នុងចំណោមនិយមន័យខុសៗគ្នាទាំងនេះអង្គការសុខភាពពិភពលោក(WHO)ប្រើប្រាស់និយមន័យមួយដែលមានលក្ខណៈសាមញ្ញ និងងាយយល់។

ការបំភាយឧស្ម័នផ្ទះកញ្ចក់ បានចាប់ផ្តើមតាំងពីសតវត្សរ៍ទី១៨។

ក្នុងរយៈពេល១០០ឆ្នាំចុងក្រោយនេះ ពិភពលោកមានកំណើនសីតុណ្ហភាព ប្រមាណ ០,៧៥អង្សាសេ និងរយៈពេល២៥ឆ្នាំ ចុងក្រោយនេះ អត្រាកំណើនកំដៅពិភពលោកបានកើនឡើងលើសពី ០,១៨អង្សាសេ ក្នុងមួយទសវត្សរ៍ (១០ឆ្នាំ)។ កំណើនសីតុណ្ហភាពនីវ៉ូទឹកសមុទ្របានកើនឡើង និងការរលាយផ្ទាំងទឹកកក បង្កឱ្យមានបញ្ហាប្រែប្រួលអាកាសធាតុ កាន់តែមានលក្ខណៈធ្ងន់ធ្ងរ និងកើតមានកាន់តែញឹកញាប់[4]។

ការគំរាមកំហែងដោយសារ "ការប្រែប្រួលអាកាសធាតុ" បានបង្ហាញយ៉ាងច្បាស់តាមរយៈការកើនឡើងនូវគ្រោះទឹកជំនន់ រាំងស្ងួត និងខ្យល់ព្យុះ ភ្លៀងខុសរដូវ ដែលបានទទួលស្គាល់ថាជាបញ្ហាប្រឈមអាទិភាពនៃការអភិវឌ្ឍន៍សកល។ ការប្រែប្រួលអាកាសធាតុមិនត្រឹមតែប៉ះពាល់ដល់បរិស្ថានធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមទៀតផង។ ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ទាំងនេះ មានលក្ខណៈខុសគ្នាតាមតំបន់ ស្ថានភាពសង្គម និងសេដ្ឋកិច្ច ព្រមទាំងរវាងស្ត្រី ក្រុមស្ត្រីងាយរងគ្រោះ និងបុរសផងដែរ។

នៅកម្ពុជា ផលប៉ះពាល់ទាំងនេះពាក់ព័ន្ធយ៉ាងខ្លាំងនឹងគ្រោះរាំងស្ងួតដែលរីករាលដាល គ្រោះទឹកជំនន់កាន់តែញឹកញាប់ សីតុណ្ហភាពកាន់តែកើនឡើង និងរបបទឹកភ្លៀងប្រែប្រួល

---

1 http://www.iea.org/topics/climatechange/

2 http://www.unep.org/climatechange/adaptation/Default.aspx

3 http://www.ipcc.ch/publications_and_data/ar4/syr/en/mains1.html

4 http://www.who.int/mediacentre/factsheets/fs266/en/

និងរដូវកាលផ្លាស់ប្តូរដែលមិនធ្លាប់កើតមានពីមុនមក។ ការប្រែប្រួលអាកាសធាតុក៏បង្កឱ្យមានកំណើនកម្ពស់ទឹកសមុទ្រ ភាពរាំងស្ងួត និងខ្យល់ព្យុះផងដែរ។ បញ្ហាទាំងនោះ មានការប៉ះពាល់លើវិស័យកសិកម្ម និងការរស់នៅរបស់សហគមន៍ជនបទភាគច្រើន និងតំបន់សហគមន៍ជនជាតិដើមភាគតិច ដោយសារប្រជាជនភាគច្រើនធ្វើស្រែចំការពឹងផ្អែកលើទឹកភ្លៀងជាប្រភពស្រោចស្រពដ៏ចម្បង ហើយការធ្វើស្រែចំការ ជាប្រភពចំណូលដ៏សំខាន់ក្នុងគ្រួសារ និងសម្រាប់ផ្គត់ផ្គង់ការហូបចុកប្រចាំថ្ងៃនៅក្នុងគ្រួសារ។ ការប្រែប្រួលអាកាសធាតុបានគំរាមកំហែងដោយផ្ទាល់លើមុខរបរចិញ្ចឹមជីវិតរបស់ប្រជាជន និងធនធានធម្មជាតិដែលជនជាតិដើមភាគតិច ជាពិសេសស្ត្រីធ្លាប់អាស្រ័យផល មិនមែនត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរយៈពេលវែងផងដែរ។

ក្នុងពេលជាមួយគ្នានេះ ការគ្រប់គ្រងធនធានធម្មជាតិមិនបានល្អ បានបង្កផលប៉ះពាល់កាន់តែធ្ងន់ធ្ងរលើសេដ្ឋកិច្ចក្នុងមូលដ្ឋាន ដោយសារសហគមន៍ភាគច្រើនពឹងផ្អែកលើអនុផលព្រៃឈើ ជាពិសេស ប្រជាជនក្នុងតំបន់ជនបទនិងសហគមន៏ជនជាតិដើមភាគតិចដែលភាគច្រើនពួកគាត់ គឺជាស្ត្រីនិងកុមារ។

ជាទូទៅ គោលនយោបាយ យុទ្ធសាស្ត្រ គម្រោង និងកម្មវិធីដែលឆ្លើយតបនឹង "ការប្រែប្រួល អាកាសធាតុ គឺពាក់ព័ន្ធនឹង"ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" និង" ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ"។

"ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" សំដៅកាត់បន្ថយភាពងាយរងគ្រោះដោយការសម្របខ្លួនក្នុងបរិស្ថានដែលកំពុងដែលកើតមាន និងការបង្កើនភាពធន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ប្រការនេះអាចអនុវត្តបានតាមរយៈការពង្រឹងសមត្ថភាពស្ថាប័នថ្នាក់ជាតិសម្រាប់ការប៉ាន់ប្រមាណភាពងាយរងគ្រោះ និងការរៀបចំផែនការបន្សាំ។ កិច្ចការនេះ ក៏មានបញ្ចូលកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិពាក់ព័ន្ធនឹងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងសកម្មភាពគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី។ ការងារទូទៅនៃ"ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" ត្រូវបានណែនាំ និងរួមចំណែកដល់កម្មវិធីការងារ ស្តីពីផលប៉ះពាល់នៅទីក្រុងណាយរ៉ូប៊ី និងភាពងាយរងគ្រោះ និងការបន្សាំ ដែលជាកម្មវិធីមួយនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)[5] ដើម្បីជួយដល់បណ្តាប្រទេស

5 https://unfccc.int/2860.php



▲ ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលផ្ទាល់ដល់ជីវភាពរបស់ប្រជាជន

នានាឱ្យយល់ដឹងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីបង្កើនលទ្ធភាពទទួលបានចំណេះដឹងសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីបរិស្ថានសហប្រជាជាតិខិតខំកៀរគរចំណេះដឹង និងការអនុវត្តន៍ល្អៗដែលមានស្រាប់នៅកម្រិតសកល តំបន់ និងជាតិ ដោយរួមបញ្ចូលបណ្តាញការបន្សាំសកល (GAN)[6] និងបណ្តាញថ្នាក់តំបន់របស់ខ្លួន[7]។

ផ្ទុយទៅវិញ "ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ" សំដៅលើការឆ្ពោះទៅរកសង្គមដែលមានបរិមាណឧស្ម័នកាបូនតិច ដោយមានការផ្តួចផ្តើមជាមុន និងសំដៅលើកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយ ឬបង្ការការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុអាចសំដៅ

6 http://www.ganadapt.org/

7 http://www.unep.org/climatechange/adaptation/Default.aspx

លើការប្រើប្រាស់បច្ចេកវិទ្យាថ្មី និងថាមពលដែលកកើតឡើងវិញ ការកែច្នៃឧបករណ៍ចាស់ៗ ឱ្យកាន់តែសន្សំសំចៃ ថាមពល និងការផ្លាស់ប្តូរសកម្មភាពគ្រប់គ្រង ឬអាកប្បកិរិយានៃការប្រើប្រាស់។

កិច្ចខិតខំប្រឹងប្រែងក្នុងពិភពលោក ផ្តើមចេញពីប្រព័ន្ធផ្លូវរថភ្លើងក្រោមដីដែលប្រើបច្ចេកវិទ្យាទំនើប រហូតដល់ផ្លូវទោចក្រយាន និងផ្លូវដើរ។ ការការពារអាងកាបូនធម្មជាតិ ដូចជាព្រៃឈើ និងមហា សមុទ្រ ឬការបង្កើនអាងកាបូនថ្មី តាមរយៈរុក្ខវប្បកម្ម[8] ឬកសិកម្មបៃតង ក៏ជាសមាសធាតុសំខាន់ នៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុនេះផងដែរ។ ជាពិសេសកម្មវិធីបរិស្ថានសហប្រជាជាតិ បានប្រើប្រាស់អភិក្រមដែលមានផ្នែកជាច្រើនសំដៅកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីជួយឱ្យបណ្តាប្រទេសនានាឆ្ពោះទៅរកសង្គមដែលមានបរិមាណឧស្ម័នកាបូនតិច[9]។

សរុបសេចក្តីមក ការប្រែប្រួលអាកាសធាតុ ធ្វើឱ្យមានបញ្ហាប្រឈម និងប៉ះពាល់ដល់ដំណើរការ ការអភិវឌ្ឍន៍ជាច្រើនដល់ប្រទេសកម្ពុជា ជាពិសេសការប៉ះពាល់ដល់ឱកាសរបស់ប្រជាជនក្រីក្រ ក្នុងរួមទាំងស្ត្រី និងកុមារដែលជាជនរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ។ ជាក់ស្តែង ស្ត្រីភាគច្រើនមិនសូវមានលទ្ធភាពពេញលេញ ក្នុងការទទួលបានធនធានហិរញ្ញវត្ថុ ដី ធនធានធម្មជាតិ ការអប់រំ សុខភាព សិទ្ធិ និងសេវាអភិវឌ្ឍន៍ផ្សេងទៀត ដែលចំណុចទាំងនេះ គឺសំខាន់សម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ សម្រាប់ស្ត្រីភាគច្រើនដែលធ្វើការនៅក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងសហគ្រាសខ្នាតតូច ការខ្វះខាតមូលធន លទ្ធភាពទទួលបានឥណទាន ព័ត៌មាន ឬចំណេះដឹង ស្ទើរតែមិនអាច រួចផុតពីផលប៉ះពាល់ធ្ងន់ធ្ងរ នៃគ្រោះមហន្តរាយបរិស្ថានទាំងនេះ[10]។

ក្នុងបរិបទនេះ ដោយសារតែការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចមានកម្រិតខ្ពស់ មានឱកាសជាច្រើនពាក់ព័ន្ធនឹង “ការអភិវឌ្ឍន៍បៃតង” សម្រាប់ស្ត្រីក្នុងរយៈពេលមធ្យម និងរយៈពេលវែង។

8 http://www.forestry.gov.uk/website/forestresearch.nsf/ByUnique/INFD-6V4BGP

9 http://www.unep.org/climatechange/mitigation/

10 ស្ត្រីរស់នៅតំបន់ជនបទ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ៖ អង្គការ Oxfam សហរដ្ឋអាមេរិក ប្រទេសកម្ពុជា ឆ្នាំ ២០១០

## ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើស្ត្រី

គណៈកម្មាធិការ ស្តីពីស្ថានភាពស្ត្រី ចាត់ទុក«ការប្រែប្រួលអាកាសធាតុ» ជាបញ្ហាថ្មី ដែលបានលើកឡើងក្នុងកិច្ចប្រជុំលើកទី៥២ ក្នុងឆ្នាំ២០០៨[11]។ អ្នកចូលរួមមកពីបណ្តាប្រទេសនានាបានទាញការយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុ ដែលបានបង្កផលប៉ះពាល់ដោយផ្ទាល់លើជីវិតរស់នៅរបស់ស្ត្រី ជាពិសេសក្រុមស្ត្រីងាយរងគ្រោះ ដោយសារតែបន្ទុកការងារផ្ទះ ការដាំស្ល តាមប្រពៃណី និងធ្វើការរកចំណូលចិញ្ចឹមជីវិតរបស់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះកាន់តែលំបាកឡើង។

គណៈកម្មាធិការនេះ បានអំពាវនាវឱ្យមានកិច្ចខិតខំប្រឹងប្រែងលើការផ្តល់ហិរញ្ញប្បទានសម្រាប់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ក្រុមស្ត្រីងាយរងគ្រោះ ជាពិសេសការផ្តោតលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើស្ត្រី និងក្មេងស្រី។

ក្រៅពីនេះ គណៈកម្មាធិការក៏បានអំពាវនាវឱ្យរាជរដ្ឋាភិបាលបញ្ចូលទស្សនវិស័យយេនឌ័រទៅក្នុងការរៀបចំ ការអនុវត្តន៍ ការពិនិត្យតាមដាន ការវាយតម្លៃ និងការរាយការណ៍ពីគោលនយោបាយជាតិស្តីពីបរិស្ថាន ពង្រឹងយន្តការ និងផ្តល់ធនធានគ្រប់គ្រាន់ដើម្បីធានាថាស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះបានចូលរួមយ៉ាងពេញលេញ និងដោយស្មើភាពក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ស្តីពីបញ្ហាបរិស្ថាន ជាពិសេសយុទ្ធសាស្ត្រពាក់ព័ន្ធនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវិតរស់នៅរបស់ស្ត្រី ក្រុមស្ត្រីងាយរងគ្រោះ និងក្មេងស្រី[12]។

នៅប្រទេសកម្ពុជា ជាពិសេសស្ត្រីនៅតំបន់ជនបទ និងក្រុមស្ត្រីងាយរងគ្រោះ ពឹងផ្អែកខ្លាំងលើធនធានធម្មជាតិ ក្នុងមូលដ្ឋានសម្រាប់ប្រកបរបរចិញ្ចឹមជីវិត ដោយសារតែការទទួលខុសត្រូវរបស់ពួកគេក្នុងការស្វែងរកទឹកប្រើប្រាស់ ចំណីអាហារ និងថាមពលសម្រាប់ចំអិន ឱសថបុរាណ និងសកម្មភាពក្នុងគ្រួសារផ្សេងទៀត។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រួមមានគ្រោះទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ភ្លៀងធ្លាក់មិនទៀងទាត់ និងការផ្លាស់ប្តូររដូវកាល ដែលធ្វើឱ្យស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះកាន់តែលំបាកក្នុងការស្វែងរកធនធានទាំងនេះ។ បើប្រៀបធៀបជាមួយបុរស ស្ត្រីជួបប្រទះឧបសគ្គជាច្រើនតាំងពីដើមមក

[11] http://www.un.org/womenwatch/daw/csw/52sess.htm

[12] កិច្ចប្រជុំលើកទី ៥២ របស់គណៈកម្មាធិការស្តីពីស្ថានភាពស្ត្រី (ឆ្នាំ២០០៨) ឯកសារបន្ថែមលេខ ៧ (E/2008/27-E/CN.6/2008/11) អង្គការសហប្រជាជាតិ ៖ http://www.un.org/womenwatch/daw/csw/52sess.htm

រួមមានកង្វះលទ្ធភាពក្នុងការធ្វើសេចក្ដីសម្រេច ការទទួលបានធនធាន ការអប់រំ ព័ត៌មាននិង អត្ថប្រយោជន៍ផ្សេងៗជាដើម ដែលប្រការទាំងអស់នេះបានបង្កជាបញ្ហាប្រឈមទៅនឹងការឆ្លើយតបការប្រែប្រួលអាកាសធាតុ[13]។

ក្នុងឆ្នាំ១៩៩១ គ្រោះមហន្តរាយខ្យល់ព្យុះស៊ីក្លូន បានសម្លាប់ប្រជាជនបង់ក្លាដេស ចំនួន១៤០.០០០នាក់ ដែលក្នុងនោះជនរងគ្រោះប្រមាណ៩០% គឺជាស្ត្រី។ ក្នុងអំឡុងនោះ អត្រាមរណភាពក្នុងចំណោមមនុស្សដែលមានអាយុ២០ទៅ៤៤ឆ្នាំគឺមានស្ត្រីចំនួន៧១នាក់ ក្នុងចំណោមស្ត្រី១.០០០នាក់ ធៀបនឹងបុរសប្រមាណ ១៥នាក់ ក្នុងចំណោមបុរស ១.០០០នាក់ដូចគ្នា។ ស្ត្រី មនុស្សវ័យក្មេង និងប្រជាជនដែលមានស្ថានភាពសេដ្ឋកិច្ចសង្គម ទាប ក៏ជាជនងាយប្រឈមនឹងហានិភ័យខ្ពស់នៃការភ័យព្រួយបារម្មណ៍ បន្ទាប់ពីការកើត មានគ្រោះមហន្តរាយផងដែរ។

ស្របពេលជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០១២ ប្រទេសកម្ពុជាមានកម្លាំងពលកម្មការងារ សរុបចំនួន ៨,៣លាននាក់[14] ប្រៀបធៀបនឹងចំនួនប្រជាជនសរុបចំនួន១៤,៨៦លាននាក់ ដែលក្នុងនោះ ស្ត្រីដើរតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ក្នុងនាមជាអ្នកចូលរួម ក្នុងទីផ្សារការងារ និងម្ចាស់អាជីវកម្ម។ វិស័យឯកជន គឺជាចលក នៃការធ្វើឱ្យវិស័យសេដ្ឋកិច្ច ជាតិរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងកំណើនជាមធ្យមប្រមាណ ៧% ក្នុងអំឡុងពីរបីឆ្នាំ កន្លងមកនេះ។ នៅឆ្នាំ ២០១២ ផលិតផលក្នុងស្រុកសរុបដែលមានតម្លៃ១៤,០៦ពាន់លាន ដុល្លារ[15] គឺបានពីវិស័យកសិកម្ម ទេសចរណ៍ សំណង់ និងឧស្សាហកម្មកម្មសាលធុនស្រាល ដូចជារោងចក្រកាត់ដេរជាដើម។

[13] កិច្ចប្រជុំលើកទី ៥២ របស់គណៈកម្មការស្តីពីស្ថានភាពស្ត្រី (ឆ្នាំ២០០៨) “ទស្សនវិស័យយេនឌ័រស្តីពីការប្រែប្រួលអាកាសធាតុ” http://www.un.org/womenwatch/daw/csw/csw52/issuespapers/ Gender%20and%20climate%20change%20paper%20final.pdf

[14] www.worldbank.org/Data/Countries/Cambodia (តាមការកំណត់របស់អង្គការអន្តរជាតិខាងការងារ កម្លាំងពលកម្មសរុប = ចំនួនមនុស្សដែលមានអាយុ ១៥ ឆ្នាំឡើងទៅ)

[15] www.worldbank.org/Data/Countries/Cambodia (ផលិតផលក្នុងស្រុកសរុប GDP ឆ្នាំ ២០១២ គិតជាដុល្លារ)



តារាងទី ១៖ ការចូលរួមកំលាំងពលកម្មរបស់ស្ត្រី និងបុរសក្នុងវិស័យសំខាន់ៗឆ្នាំ ២០១២ (ជាភាគរយ)

| វិស័យសំខាន់ៗ | ស្ត្រី | បុរស |
|---|---|---|
| កសិកម្ម | ៥២,៨ | ៤៩,៣ |
| ឧស្សាហកម្ម | ១៨,១ | ១៩,០ |
| សេវាកម្ម | ២៩,១ | ៣១,៧ |

(ប្រភព៖អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ ២០១២)

▲ ស្ត្រីមានឱកាសជាច្រើនទាក់ទងនឹងការអភិវឌ្ឍន៍បៃតង

អត្រាចូលរួមក្នុងកម្លាំងពលកម្មសរុប ដែលជាសមាមាត្រកម្លាំងពលកម្មសកម្មខាងវិស័យសេដ្ឋកិច្ច ដែលមានអាយុ១៥ឆ្នាំឡើងទៅ មានប្រមាណ ៧១%។ យោងតាមទិន្នន័យបែងចែកតាមភេទ អត្រាចូលរួមក្នុងកម្លាំងពលកម្ម

របស់ស្ត្រី មានប្រមាណ៧៩%[16]។ ក្នុងចំណោមវិស័យសេដ្ឋកិច្ចសំខាន់ៗទាំងអស់ភាគរយស្ត្រីដែលចូលរួមក្នុងការងារកសិកម្ម មានប្រមាណ៥៣%។ ស្ត្រីប្រមាណ៧៣% ស្ថិតនៅក្នុងស្ថានភាពការងារដែលងាយរងគ្រោះ មានន័យថាការងារស្ត្រីចំនួន៣ ក្នុងចំណោមការងារចំនួន៤ ក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ថ្នាក់ជាប្រភេទការងារដែលងាយរងគ្រោះ។ ទោះបីជាភាពងាយរងគ្រោះទាំងនេះ កើតមានភាគច្រើនក្នុងខ្សែសង្វាក់តម្លៃសេដ្ឋកិច្ចពិភពលោកក៏ដោយ ប៉ុន្តែភាពងាយរងគ្រោះទាំងនោះកាន់តែមានលក្ខណៈធ្ងន់ធ្ងរតាមរយៈផលប៉ះពាល់នៃ "ការប្រែប្រួលអាកាសធាតុ"។

ក្រៅពីការចូលរួមចំណែកយ៉ាងច្រើនក្នុងកម្លាំងពលកម្ម ស្ត្រីធ្វើជាម្ចាស់ និងគ្រប់គ្រងសហគ្រាសខ្នាតតូចជាច្រើន។ យោងតាមការអង្កេត"ជំរឿនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១១"[17] ក្នុងប្រទេសកម្ពុជា មានគ្រឹះស្ថានអាជីវកម្ម ចំនួន៥០០.០០០ ដែលក្នុងនោះគ្រឹះស្ថានអាជីវកម្ម ៦៥ភាគរយ គ្រប់គ្រង និងដំណើរការដោយស្ត្រី[18]។ ទោះជាយ៉ាងណា ស្រដៀងគ្នាទៅនឹងស្ថិតិទីផ្សារការងារ ទិន្នន័យបានបង្ហាញថាគ្រឹះស្ថានអាជីវកម្មភាគច្រើនមានលក្ខណៈតូចតាច និងក្រៅប្រព័ន្ធ ដែលមានស្ត្រីជាម្ចាស់ខ្លួនឯងដោយមិនមាន ឬមាននិយោជិកតិច។

មានការបង្ហាញយ៉ាងច្បាស់ថា តាមរយៈផលប៉ះពាល់នៃ"ការប្រែប្រួលអាកាសធាតុ" ដូចជាទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងកំណើនសីតុណ្ហភាពជាដើម របរចិញ្ចឹមជីវិតរបស់ស្ត្រី និងគ្រួសាររបស់ពួកគេកំពុងប្រឈមនឹងហានិភ័យ ដោយស្ត្រីភាគច្រើនពឹងផ្អែកលើវិស័យកសិកម្ម និងឧស្សាហកម្មក្នុងតំបន់ជនបទ ហើយជាពិសេសបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរជនជាតិដើមភាគតិច ដែលពួកគាត់បានពឹងផ្អែកទាំងស្រុងលើការដាំដុះបែបប្រពៃណីនិងធនធានធម្មជាតិ។

ការគំរាមកំហែងនេះ  គឺជាបញ្ហាប្រឈមនៅក្នុង"ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" "ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ" ដូចជា"ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG)" និង"ការអភិវឌ្ឍន៍បៃតង"ជាដើម។ ហេតុដូច្នេះ "ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE)" និង "ការប្រែប្រួលអាកាសធាតុ" មានលក្ខណៈពាក់ព័ន្ធគ្នាដោយផ្ទាល់ និងបង្កើតឱកាសក្នុងការឆ្ពោះទៅរកសង្គមមួយដែលមានបរិមាណឧស្ម័នកាបូនតិច[19]។

---

16 www.worldbank.org/Data/Countries/Cambodia (អត្រាចូលរួមក្នុងកម្លាំងពលកម្ម (សរុប ទាំងស្ត្រីនិង បុរស) គឺជាភាគរយនៃមនុស្សដែលអាយុ ១៥ ឆ្នាំឡើងទៅ)

17 ជំរឿនសេដ្ឋកិច្ចកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ/អង្គការ JICA ឆ្នាំ២០១១

18 ការអង្កេតពីប័ណ្ណពិន្ទុបរិស្ថានអាជីវកម្មតាមខេត្តក្នុងប្រទេសកម្ពុជា មូលនិធិអាស៊ី ឆ្នាំ២០០៩

19 http://www.unep.org/climatechange/mitigation/

## ការកាត់បន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

ជាសកល រដ្ឋាភិបាលបានសន្យាក្នុងការខិតខំប្រឹងប្រែងជាបន្តបន្ទាប់សម្រាប់បច្ចេកវិទ្យាបៃតងថ្មី ដោយអះអាងថាសកម្មភាពរបស់រដ្ឋាភិបាលក្នុងការបង្កើត"ការងារបៃតង" មិនត្រឹមតែមាននិរន្តរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយស្តារសេដ្ឋកិច្ចថែមទៀតផង។ យោងតាមរបាយការណ៍ថ្មីៗរបស់អង្គការពលកម្មអន្តរជាតិ[20]បានឱ្យដឹងថា តាមរយៈមូលនិធិរដ្ឋ ការងារបៃតងក្នុងវិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងរដ្ឋបាលបានជំរុញឱ្យមានកំណើនសេដ្ឋកិច្ចដែលមាននិរន្តរភាព ព្រមទាំងផលប៉ះពាល់ជាវិជ្ជមានផ្នែកសេដ្ឋកិច្ចរយៈពេលវែង។

ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យមានការផ្លាស់ប្តូរឆ្ពោះទៅរកគំរូថ្មីៗនៃផលិតកម្ម ការប្រើប្រាស់ និងការងារ។ ឱកាសដ៏ច្រើនមានរួចជាស្រេចក្នុងការបង្កើតការងារបៃតង តាមរយៈគោលនយោបាយ ស្តីពីថាមពល និងឧស្សាហូបនីយកម្មដែលកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ ការងារទាំងនេះ អាចបង្កើតការងារសមរម្យ និងប្រាក់ចំណូល ដែលនឹងរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះដែលមានចំណេះដឹង និងសមត្ថភាពពិសេសក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការប្រើប្រាស់ប្រភពថាមពល អាចជា"ភ្នាក់ងារផ្លាស់ប្តូរ" ដ៏រឹងមាំ និងជាអ្នករួមចំណែកដ៏សំខាន់ក្នុងកម្មវិធីកាត់បន្ថយផលប៉ះពាល់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅគ្រប់កម្រិតទាំងអស់។ ជាទូទៅ ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះមានទំនួលខុសត្រូវយ៉ាងច្រើនក្នុងគ្រួសារ សហគមន៍ និងជាអ្នកគ្រប់គ្រងធនធានធម្មជាតិ។ នេះជាឱកាសសម្រាប់ស្ត្រី "អាចបញ្ចេញមតិ" ពីបញ្ហា តម្រូវការ ការទទួលខុសត្រូវ ការទទួលបានធនធាននិងការប្រើប្រាស់ធនធាន និងការធ្វើសេចក្តីសម្រេច ក្នុងការបង្កើតយុទ្ធសាស្ត្រសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលបរិស្ថាន និងបង្កើតគំនិតច្នៃប្រឌិត ពោលគឺសកម្មភាពសេដ្ឋកិច្ច"បៃតង"។ បទពិសោធន៍បានបង្ហាញថាសហគមន៍មានដំណើរការល្អប្រសើរក្នុងអំឡុងពេលមានគ្រោះមហន្តរាយធម្មជាតិ នៅពេលដែលស្ត្រីដើរតួនាទីជាអ្នកដឹកនាំក្នុងប្រព័ន្ធផ្តល់ព័ត៌មានជាមុន និងការស្តារឡើងវិញ។ ស្ត្រីមានគោលបំណងចែករំលែក

---

[20] "ការងារបៃតងៈធ្វើឱ្យប្រសើរឡើងនូវអាកាសធាតុដើម្បីសមភាពយេនឌ័រ!" អង្គការពលកម្មអន្តរជាតិ ការិយាល័យសម្រាប់សមភាពយេនឌ័រ (ខែមករា ឆ្នាំ២០០៩) www.ilo.org/gender (សៀវភៅបោះពុម្ព)

ព័ត៌មានពាក់ព័ន្ធនឹងសុខុមាលភាពរបស់សហគមន៍ ជ្រើសរើសប្រភេទពូជថាមពលដែលបំពុលតិច និងបន្សាំកាន់តែងាយស្រួលទៅនឹងការប្រែប្រួលបរិស្ថាននៅពេលដែលគ្រួសាររបស់ពួកគេប្រឈមនឹងហានិភ័យ[21]។

កាលពីខែមីនា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាបានផ្សព្វផ្សាយ "គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍បៃតង"[22] ដែលសំដៅ "ជំរុញឱ្យមានតុល្យភាពរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ចបរិស្ថានសង្គម និងវប្បធម៌ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ដែលមាននិរន្តរភាព"។

មុនពេលអនុវត្តគោលនយោបាយជាតិ ស្តីពីអភិវឌ្ឍបៃតង ក្នុងខែវិច្ឆិកា ឆ្នាំ២០១១ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសមភាពយេនឌ័រក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិកលើកទី៤ ស្តីពី"ការបង្កើនភាពធន់ទៅនឹងវិបត្តិសេដ្ឋកិច្ចនិងដំណើរឆ្ពោះទៅមុខ" ដែលបានរៀបចំឡើង នៅក្នុងខេត្តសៀមរាប[23] បានលើកឡើងអនុសាសន៍ ដូចខាងក្រោមសម្រាប់ប្រទេសកម្ពុជា ស្តីពី "សេដ្ឋកិច្ចបៃតង" ៖

- សហគ្រិនជាស្ត្រី៖ គួរមានការពង្រឹងយន្តការ ដូចជាសមាគមអាជីវកម្មស្ត្រី ដើម្បីជំរុញសហគ្រិនភាព ការទទួលបានព័ត៌មានពាក់ព័ន្ធនឹងអាជីវកម្ម បច្ចេកវិទ្យាបៃតង និងសេវាហិរញ្ញវត្ថុ។
- កសិកម្មសរីរាង្គ និងមាននិរន្តរភាព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរបង្កើតក្របខណ្ឌគោលនយោបាយ និងកម្មវិធីស្តីពីកសិកម្មសរីរាង្គ។ សេវាផ្សព្វផ្សាយកសិកម្មគួរផ្តោត លើកសិករជាស្ត្រី និងក្រុមស្ត្រីដែលសកម្ម និងមានគំនិតផ្តួចផ្តើមជាមុន។
- លទ្ធកម្មបៃតង៖ គួរមានការផ្តោតលទ្ធកម្មវិស័យសាធារណៈលើផលិតផល និងសេវាបៃតង ជាពិសេសចំណីអាហារ (សរីរាង្គនិងមិនមានជាតិគីមី) ដែលផលិតឡើងដោយមាននិរន្តរភាព និងផលិតផលផ្សេងទៀតសម្រាប់ស្ថាប័នរាជរដ្ឋាភិបាល សាលារៀន មន្ទីរពេទ្យ និងស្ថានទូត តាមដែលអាចធ្វើទៅបាន។ គួរផ្តល់អាទិភាពដល់សហគ្រាសដែលគ្រប់គ្រងដោយស្ត្រី។

---

21 "សមភាពយេនឌ័រជាចំណុចស្នូលនៃការងារសមរម្យ" អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០០៩ gendercampaign@ilo.org

22 គោលនយោបាយជាតិស្តីពីអភិវឌ្ឍបៃតង ក្រុមប្រឹក្សាជាតិស្តីពីអភិវឌ្ឍបៃតង រាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៣

23 កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីសមភាពយេនឌ័រក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិកលើកទី៤ "ការបង្កើនភាពធន់នឹងវិបត្តិ សេដ្ឋកិច្ច និងដំណើរឆ្ពោះទៅមុខ" របាយការណ៍ចុងក្រោយរបស់ក្រសួងកិច្ចការនារី សណ្ឋាគារ Angkor Century ខេត្តសៀមរាប ប្រទេសកម្ពុជា ថ្ងៃទី ១៧-១៨ ខែ វិច្ឆិកា ឆ្នាំ២០១១



▲ បម្រែបម្រួលអាកាសធាតុធ្វើឱ្យកើនឡើងនូវភាពរាំងស្ងួត ព្យុះ និងទឹកជំនន់

- ភាពជាដៃគូរវាងវិស័យឯកជននិងសាធារណៈ (PPP)៖ ការលើកកម្ពស់ភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈនឹងក្លាយជាយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់ការលើកកម្ពស់ "ការអភិវឌ្ឍន៍បៃតង"។ ចាំបាច់ត្រូវមានការកែសម្រួលក្របខណ្ឌគតិយុត្ត ដើម្បីផ្ដល់ការលើកទឹកចិត្តសមស្របនិងការស្រាវជ្រាវគោលនយោបាយតាមវិស័យដើម្បីកំណត់ឱកាសសំខាន់ៗបំផុត។

សរុបសេចក្ដីមក "ការផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី" ក្នុងបរិបទ "ការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ" និង "ការអភិវឌ្ឍន៍បៃតង" កំពុងទទួលបានការយកចិត្តទុកដាក់កាន់តែច្រើនឡើងសម្រាប់ទស្សនវិស័យជាយុទ្ធសាស្ត្រនាពេលអនាគតរបស់ក្រសួងកិច្ចការនារី។

ការផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះបានបង្កើនសក្ដានុពលយ៉ាងច្រើនលើសលុបសម្រាប់ការបង្កើតផលិតផល

និងសេវា "បៃតង" រួមមានហិរញ្ញវត្ថុ ជំនាញ និងជាពិសេស "ចំណេះដឹងនិងព័ត៌មាន" ពីរបៀបចាប់ផ្តើម គ្រប់គ្រង និងការពង្រីកអាជីវកម្ម "បៃតង" ដែលមានការប្រកួតប្រជែងនិងមាននិរន្តរភាព។ បន្ថែមពីនេះ ស្ត្រីនឹងទទួលបានការជំរុញលើកទឹកចិត្តយ៉ាងទូលំទូលាយក្នុងការចាប់ផ្តើម និងកែលម្អអាជីវកម្មរបស់ខ្លួន ក្នុងនាមជា"សហគ្រិន" ដោយហេតុនេះផលិតភាពចាំបាច់ បន្ទាន់ ការច្នៃប្រឌិត និងការងារអាចបង្កើតឡើងដោយស្ត្រី និងសម្រាប់ស្ត្រី។

## ស្ត្រី សមភាពយេនឌ័រ និងថាមពល

ថាមពល គឺជាផ្នែកដ៏សំខាន់មួយ ហើយជារឿយៗថាមពលកកើតឡើងវិញ គឺជាបច្ចេកវិទ្យាដ៏សំខាន់ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ មានការលើកឡើងជាច្រើន ទាក់ទងនឹងតួនាទីរបស់ស្ត្រីក្នុងបញ្ហាថាមពល ដែលក្នុងនោះថាមពលចម្បងរួមមានភ្លើងអគ្គិសនីដើម្បីដំណើរការឧបករណ៍ និងសម្ភារៈ ប្រេងសាំង និងប្រេងម៉ាស៊ូតសម្រាប់យានជំនិះ និងការផលិតប្រេងសម្រាប់ផលិតឧស្ម័នធម្មជាតិ។ ជាទូទៅ ការដោះស្រាយបញ្ហាខុសៗគ្នាទាំងនេះ (ភ្លើងអគ្គិសនី និងប្រេងឥន្ធនៈ) ត្រូវបានចាត់ទុកជាការងាររបស់បុរស ខណៈដែលស្ត្រីមិនត្រូវបានរំពឹងថានឹងចូលរួមក្នុងការងារផលិតថាមពល និងចែកចាយប្រេងឥន្ធនៈនោះឡើយ[24]។

តាមរយៈលទ្ធផលនៃការពិចារណាទាំងនេះ ស្ត្រី ក្រុមស្ត្រីងាយរងគ្រោះ និងបុរសប្រឈមនឹងភាពខុសៗគ្នាក្នុងការបណ្តុះបណ្តាល និងការរំពឹងទុកពីសង្គម ដែលការចូលរួមរបស់ស្ត្រីនៅមានកម្រិតនៅក្នុងកិច្ចពិភាក្សាពីផែនការ និងគោលនយោបាយថាមពលក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

កង្វះនូវការទទួលស្គាល់តួនាទីរបស់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះក្នុងវិស័យថាមពលធ្វើឱ្យនយោបាយថាមពល "មិនបានយកចិត្តទុកដាក់លើយេនឌ័រ" (ឬអាចនិយាយបានថាមិនមានការពិចារណាពី យេនឌ័រ) ដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ ឬមិនមាននិរន្តរភាពសេដ្ឋកិច្ច និងសង្គមភាគច្រើនកើតមាននៅក្នុងគម្រោងថាមពលវារីអគ្គិសនីខ្នាតធំ។

---

[24] ការងារពាក់ព័ន្ធនឹងថាមពលគឺជាកិច្ចការរបស់ស្ត្រី ៖ របាយការណ៍ជាតិ និងតំបន់ពីទ្វីបអាហ្វ្រិក អាស៊ី អាមេរិកឡាទីន និងប៉ាស៊ីហ្វិក http://www.energia.org/fileadmin/files/media/pubs/karlsson_csdbook_lores.pdf

ទំនាក់ទំនងរវាងការផ្គត់ផ្គង់ថាមពល តួនាទីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ គឺជាកត្តាដ៏រឹងមាំបំផុតក្នុងតំបន់ដែលមិនសូវមានភ្លើងអគ្គិសនីប្រើប្រាស់ និងឥន្ទនៈទំនើប ព្រមទាំងការពឹងផ្អែកខ្ពស់លើ ថាមពលជីវម៉ាសជាប្រពៃណី ដូចជាអុស ធ្យូង និងកាកសំណល់កសិកម្មជាដើម សម្រាប់ការចំអិន ការកំដៅ និងការបំភ្លឺ។ ការស្វែងរក និងការគ្រប់គ្រងឥន្ទនៈទាំងនេះ គឺជា"កិច្ចការរបស់ស្ត្រី" ភាគច្រើន។ ដោយសារតែផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការប្រែប្រួលបរិស្ថាន ស្ត្រីហាក់ដូចជាចំណាយពេលច្រើនក្នុងការស្វែងរក ឱសថ បន្លែ ផ្លែឈើ អុស ដងទឹក ធ្វើការងារកសិកម្ម ផ្តល់ការថែទាំ និងចំអិនអាហារសម្រាប់គ្រួសារ កូន និងមនុស្សចាស់ជរា។

ដោយសារការទទួលខុសត្រូវ និងកិច្ចការដ៏ច្រើនទាំងនេះ ស្ត្រីគួរចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងថាមពលនៅថ្នាក់ជាតិនិងក្រោមជាតិ។ ស្ត្រីគួរចូលរួមកាន់តែច្រើន ដើម្បីអាចឱ្យការគ្រប់គ្រង ការផ្គត់ផ្គង់ថាមពលកាន់តែមានប្រសិទ្ធភាព និងសមស្រប ក្នុងស្ថានភាពនៃការប្រែប្រួលអាកាសធាតុ។

## ការប្រែប្រួលអាកាសធាតុ និងសុខភាពស្ត្រី

ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បានលើកឡើងថា "ការប្រែប្រួលអាកាសធាតុ នឹងបង្កការគំរាមកំហែងកាន់តែធ្ងន់ធ្ងរដល់សុខភាពមនុស្ស"។

ការប្រែប្រួលអាកាសធាតុអាចបង្កផលប៉ះពាល់ដល់សុខភាពមនុស្សដោយផ្ទាល់ ដូចជាផលប៉ះពាល់លើភាពតានតឹងផ្លូវអារម្មណ៍ដោយសារតែការឡើងកំដៅសកល ការស្លាប់ ឬការរងគ្រោះដោយសារទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។ ការប៉ះពាល់ដោយប្រយោល តាមរយៈការប្រែប្រួលយ៉ាងច្រើននូវភ្នាក់ងារចម្លងជំងឺ (សត្វមូស) មេរោគបង្កជំងឺក្នុងទឹក គុណភាពទឹក គុណភាពខ្យល់ និងគុណភាពអាហារជាដើម។ ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុក៏បានលើកឡើងថាផលប៉ះពាល់សង្គមនឹងមានភាពខុសគ្នា ទៅតាមអាយុ ឋានៈ សង្គម សេដ្ឋកិច្ច ការងារ និងយេនឌ័រ ហើយប្រជាជនក្រីក្របំផុតក្នុងពិភពលោកនឹងទទួលរងផលប៉ះពាល់ធ្ងន់ជាងគេបំផុត[25]។

[25] ឯកសារពិភាក្សាព្រាងស្តីពីយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងសុខភាពរបស់អង្គការសុខភាពពិភពលោក http://www.who.int/phe/en/

ការប្រែប្រួលអាកាសធាតុប៉ះពាល់សុខភាពផ្នែកសង្គម និងបរិស្ថានភាគច្រើន រួមមាន ខ្យល់អាកាសបរិសុទ្ធ ទឹកពិសារមានសុវត្ថិភាព ចំណីអាហារគ្រប់គ្រាន់ និងជម្រកសុវត្ថិភាព[26] ជាដើម។

យោងតាមរបាយការណ៍ថ្មីមួយរបស់អង្គការសុខភាពពិភពលោក (WHO)[27] ប្រជាជន ៧លាននាក់ បានស្លាប់ជារៀងរាល់ឆ្នាំ ដោយសារតែការបំពុលខ្យល់ ពោលគឺការបំពុលខ្យល់ បានធ្វើឱ្យមានការស្លាប់មួយករណី ក្នុងចំណោមការស្លាប់ប្រាំបីករណីទូទាំងពិភពលោក ដែលប្រការនេះបានធ្វើឱ្យការបំពុលខ្យល់ក្លាយជាហានិភ័យសុខភាពបរិស្ថានដ៏ធំមួយលើ ផែនដី។ លទ្ធផលរកឃើញរបស់របាយការណ៍នេះ បានលើកឡើងពីទំនាក់ទំនងរវាង ការបំពុលខ្យល់នឹងជំងឺបេះដូង បញ្ហាផ្លូវដង្ហើម និងជំងឺមហារីក។

"ស្ត្រី និងកុមារក្រីក្រទទួលរងគ្រោះយ៉ាងខ្លាំងពីការបំពុលខ្យល់ក្នុងផ្ទះ ដោយសារតែ ពួកគេត្រូវចំណាយពេលច្រើននៅផ្ទះ និងស្រូបយកផ្សែងលម្អងផ្សែងពីធ្យូង និងចង្រ្កាន ប្រើអុសដែលហុយ"[28]។

ជាសកល ចំនួនគ្រោះមហន្តរាយធម្មជាតិដែលពាក់ព័ន្ធនឹងអាកាសធាតុបានកើនឡើង ច្រើនជាង៣ដង តាំងពីទស្សវត្សរ៍ឆ្នាំ១៩៦០។ កំណើននីវ៉ូទឹកសមុទ្រ និងការកើនឡើងនៃ ព្រឹត្តិការណ៍ធាតុអាកាសអាក្រក់នឹងបំផ្លាញផ្ទះសម្បែង មណ្ឌលសុខភាព និងសេវាសំខាន់ៗ ផ្សេងទៀត។ ប្រជាជនអាចនឹងបង្ខំចិត្តចាកចេញ ដែលនឹងបន្ថែមហានិភ័យនៃផលប៉ះពាល់ ដល់សុខភាពកាន់តែច្រើនថែមទៀត ចាប់ពីបញ្ហាផ្លូវចិត្តរហូតដល់ជំងឺឆ្លង។

មានភស្តុតាងមួយចំនួនបានបង្ហាញថាស្ត្រី និងបុរសរងគ្រោះពីបញ្ហាសុខភាពខុសៗគ្នា បន្ទាប់ពីការកើតមានគ្រោះធម្មជាតិ ដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងរលកកំដៅ។ កំណើនសីតុណ្ហភាពនឹងបង្កើនការចម្លងជំងឺគ្រុនចាញ់ដែលបានធ្វើឱ្យប្រជាជនប្រមាណ ៣០០លាននាក់ មានជំងឺទាន់ហន់ភ្លាមៗ និងបានសម្លាប់ប្រជាជន១លាននាក់ ជារៀងរាល់ ឆ្នាំទូទាំងពិភពលោក។ ស្ត្រីមានផ្ទៃពោះ គឺងាយរងគ្រោះទៅនឹងជំងឺគ្រុនចាញ់ ដោយសារ គាត់"ងាយ" នឹងត្រូវបានសត្វមូសដែលផ្ទុកមេរោគគ្រុនចាញ់ខាំពីរដងច្រើនជាងស្ត្រីមិន មានផ្ទៃពោះ[29]។

---

[26] http://www.who.int/mediacentre/factsheets/fs266/en/
[27] http://www.who.int/phe/health_topics/outdoorair/databases/en/
[28] http://www.bbc.com/news/health-26730178
[29] ការទាក់ទាញដល់សត្វមុសចំពោះស្ត្រីមានផ្ទៃពោះ, The Lancet, លេខទី ៩២៣០, ទំព័រទី ៦៨៥, ថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០០០, Espinosa, Duarte Alecrim, Daniel-Ribeiro, (2000)

ការសិក្សាបានបង្ហាញថាកំណើនសីតុណ្ហភាព២អង្សាសេអាចកាត់បន្ថយទិន្នផលគ្រាប់ធុញ្ញជាតិពី ៥ភាគរយ ទៅ២០ភាគរយក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលប្រការនេះបានធ្វើឱ្យបញ្ហាកង្វះអាហារូបត្ថម្ភ និងបញ្ហាសុខភាពកាន់តែមានលក្ខណៈធ្ងន់ធ្ងរ ជាពិសេសការអភិវឌ្ឍរាងកាយ និងប្រាជ្ញាស្មារតីរបស់កុមារ។ សម្រាប់ប្រជាជននៅទីក្រុងភាគច្រើន មានការប៉ាន់ប្រមាណថាកំណើនសីតុណ្ហភាព២អង្សាសេអាចបង្កើនអត្រាមរណភាពប្រចាំឆ្នាំដោយសាររលកកំដៅកើនឡើងប្រហែលពីរដង។

គ្រោះទឹកជំនន់ គឺជាគ្រោះថ្នាក់អាកាសធាតុដែលរីករាលដាលធំបំផុតមួយ បង្កហានិភ័យដល់សុខភាពរបស់មនុស្ស។ នៅប្រទេសកម្ពុជា ទឹកជំនន់កើតមានកាន់តែច្រើនឡើង និងមានលក្ខណៈកាន់តែធ្ងន់ធ្ងរ។ ទឹកជំនន់បានធ្វើឱ្យប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកស្អាត បន្ថែមហានិភ័យនៃជំងឺឆ្លងតាមទឹក ដែលចម្លងតាមរយៈសត្វល្អិត ខ្យង ឬសត្វឈាមត្រជាក់។ សំខាន់ជាងនេះទៅទៀត ទឹកជំនន់បានបង្កឱ្យមានការលង់ទឹក ការរងរបួស បំផ្លិចបំផ្លាញផ្ទះសម្បែង និងរំខានការផ្គត់ផ្គង់សេវាសុខភាព រួមមានការផ្តល់សេវាសំខាន់ៗសម្រាប់សុខភាពមាតា និងទារក ចាស់ជរា ជនពិការ។ល។

របាយការណ៍គ្រោះមហន្តរាយពិភពលោក[30] ទទួលស្គាល់មតិជាទូទៅថា "ស្ត្រី និងក្មេងស្រីងាយប្រឈមនឹងហានិភ័យខ្ពស់នៃអំពើហិង្សាផ្លូវភេទ ការកេងប្រវ័ញ្ច និងការបំពានផ្លូវភេទ ការជួញដូរ និងអំពើហិង្សាក្នុងគ្រួសារក្នុងពេលកើតមានគ្រោះមហន្តរាយ" ក្នុងពេលជាមួយគ្នានោះ ស្ត្រីត្រូវបានបំបែកចេញពីគ្រួសារ មិត្តភក្តិ និងការគាំទ្រសំខាន់ៗផ្សេងទៀត និងប្រព័ន្ធគាំពារ ហេតុដូចនេះដោយសារតែការភ័យខ្លាចធ្វើឱ្យស្ត្រីជៀសវាងការប្រើប្រាស់ទីជម្រករួម។ ស្ត្រីប្រឈមនឹងភាពតានតឹងផ្លូវចិត្ត បន្ទាប់ពីគ្រោះមហន្តរាយ ជាពិសេសក្នុងករណីដែលគ្រួសារត្រូវបានជម្លៀស និងរស់នៅក្នុងស្ថានភាពបន្ទាន់នៅទីជម្រកបណ្តោះអាសន្ន។ ស្ត្រីមានការលំបាកក្នុងការសម្របខ្លួនទៅក្នុងបរិយាយកាសរស់នៅក្នុងជម្រកថ្មី ដូចជាភាពអ៊ូអរ ការខ្វះខាតភាពឯកជន ការបាត់បង់ទម្លាប់ប្រចាំថ្ងៃ ការប្រកបរបរចិញ្ចឹមជីវិត ការខកបំណង និងអំពើហិង្សា ហេតុដូច្នេះហើយស្ត្រី និងសមាជិកក្នុងបន្ទុកគ្រួសារ គឺជាអ្នកដែលងាយរងគ្រោះបំផុតពេលមានគ្រោះអាសន្ន ឬគ្រោះមហន្តរាយធម្មជាតិ។ ពេលខ្វះស្បៀង ស្ត្រីសុខចិត្តហូបតិច ដើម្បីទុកលទ្ធភាពឱ្យបុរស និងកូនហូបឆ្អែត ដែលជាហេតុនាំឱ្យស្ត្រីខ្វះអាហាររូបត្ថម្ភ និងសុខភាពទ្រុឌទ្រោម។

30 របាយការណ៍គ្រោះមហន្តរាយពិភពលោក សហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម (IFRC) ទីក្រុងហ្សឺណែវ ឆ្នាំ២០០៧

ក្នុងឆ្នាំ២០០៩ សន្និបាតសុខភាពពិភពលោក បានអនុម័តផែនការការងារថ្មីមួយរបស់អង្គការសុខភាពពិភពលោក ស្តីពីការប្រែប្រួលអាកាសធាតុនិងសុខភាព[31]។ ផែនការការងារនេះ មានបញ្ចូលៈ

ការស្វែងរកការគាំទ្រមតិៈ លើកកម្ពស់ការយល់ដឹងថាការប្រែប្រួលអាកាសធាតុ គឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរដល់សុខភាពមនុស្ស។

ភាពជាដៃគូៈ សម្របសម្រួលជាមួយទីភ្នាក់ងារដៃគូក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ និងធានាថាបញ្ហាសុខភាពត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវក្នុងរបៀបវារៈ ស្តីពីការប្រែប្រួលអាកាសធាតុ។

វិទ្យាសាស្ត្រ និងភស្តុតាងៈ សម្របសម្រួលការពិនិត្យឡើងវិញលើភស្តុតាងវិទ្យាសាស្ត្រ ស្តីពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងសុខភាព ព្រមទាំងបង្កើតរបៀបវារៈស្រាវជ្រាវសកលមួយ។

ការពង្រឹងប្រព័ន្ធសុខាភិបាលៈ ជួយដល់បណ្តាប្រទេសនានាក្នុងការប៉ាន់ប្រមាណភាពងាយរងគ្រោះផ្នែកសុខភាព និងកសាងសមត្ថភាពក្នុងការកាត់បន្ថយភាពងាយរងគ្រោះផ្នែកសុខភាពទៅនឹងការប្រែប្រួលអាកាសធាតុ។

## ផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCSP)[32]

ផ្អែកតាមក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងខែកុម្ភៈ ឆ្នាំ២០១៣ ក្រសួងកិច្ចការនារីបានអនុម័តផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ដែលត្រូវបានរៀបចំដោយគណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCC) ដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។

ផែនការយុទ្ធសាស្ត្រនេះ ផ្តោតជាចម្បងលើ"ការបញ្ជ្រាបយេនឌ័រ និងគម្រោងអនុវត្តសាកល្បង" ដែលបានបន្សុីទៅនឹងគោលនយោបាយថ្នាក់ជាតិពាក់ព័ន្ធ រួមមាន"យុទ្ធសាស្ត្រចតុកោណ" ដំណាក់កាលទី៣[33] គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs)

---

[31] http://www.who.int/globalchange/health_policy/wha_eb_documentation/A63_27_en_climate_change.pdf

[32] ផែនការយុទ្ធសាស្ត្រស្តីពី យេនឌ័រនិងការប្រែប្រួលអាកាសធាតុ (GCCSP/ឆ្នាំ២០១៣-២០២៣) ក្រសួងកិច្ចការនារី ខែ កុម្ភៈ ឆ្នាំ២០១៣

[33] http://cnv.org.kh/en/wp-content/uploads/2013/10/26sep13_rectangular-strategy_phaseIII.pdf

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ឆ្នាំ២០១៤-២០១៨) និងផែនការយុទ្ធសាស្ត្រ៥ឆ្នាំនារីរតនៈទី៤ (ឆ្នាំ២០១៤-២០១៨) ដោយផ្តោតលើការអភិវឌ្ឍសមត្ថភាព និងតួនាទីរបស់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះដែលពាក់ព័ន្ធនឹងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

ក្រសួងកិច្ចការនារី នឹងសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ដោយសហការ និងប្រើប្រាស់យន្តការដែលមានស្រាប់ ដូចជាគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រុមការងារបញ្ជ្រាបយេនឌ័រ(GMAGs) របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ជាដើម។ លើសពីនេះ ក្រសួងកិច្ចការនារីមានលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) ដែលមានសមាសភាពដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ តំណាងវិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយ សាកលវិទ្យាល័យ និងអង្គការសាសនា។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងកិច្ចការនារីបានបង្កើតក្រុមការងារតូចសម្រាប់ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE) និងជាវេទិកាពិភាក្សាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុផងដែរ។

ជារួម ផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុរបស់ក្រសួងកិច្ចការនារី មានសមាសធាតុសំខាន់ៗដូចខាងក្រោម៖

១. ជំរុញការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច ស្តីពីការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិនៅគ្រប់កម្រិត និងគ្រប់វិស័យ។

២. ការធ្វើការប៉ាន់ប្រមាណសមត្ថភាពក្រសួង ស្ថាប័នពាក់ព័ន្ធ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ និងការរៀបចំវិធីសាស្ត្រសម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។

៣. លើកកម្ពស់នៃការយល់ដឹងស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុដល់ថ្នាក់ដឹកនាំ

មន្ត្រី របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងក្រោមជាតិ និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

៤. អនុវត្តគម្រោងសាកល្បងក្នុងការបន្សាំ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងភាពអង់អាចដល់ស្ត្រី ដូចជាលើកកម្ពស់ជីវភាពរស់នៅ សន្តិសុខស្បៀង អាហារូបត្ថម្ភ សុខភាពនិងអនាម័យ ការទទួលបានទឹកស្អាត ការគ្រប់គ្រងកាកសំណល់ ការទទួលបានព័ត៌មាន និងការបង្កើតក្រុមគាំទ្រ ។

៥. ការស្រាវជ្រាវ និងចងក្រងទិន្នន័យ និងព័ត៌មានស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

៦. ចងក្រង និងផ្សព្វផ្សាយការអនុវត្ត និងបទពិសោធន៍ល្អៗ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុសម្រាប់បង្កើនការរៀនសូត្រ និងការចែករំលែកដល់អ្នកពាក់ព័ន្ធ។

## ផែនការសកម្មភាព ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ[34]

ផ្អែកលើផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ មានដំណើរការពិគ្រោះយោបល់ជាបន្តបន្ទាប់សម្រាប់ការបង្កើតផែនការសកម្មភាព ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ (GCCAP) ៥ឆ្នាំ (ឆ្នាំ២០១៤-២០១៨)។ ផែនការសកម្មភាពនេះមានគោលបំណងអនុវត្តអនុសាសន៍ នៃផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ដោយផ្តោតទៅលើស្ត្រី និងក្រុមជនងាយរងគ្រោះផ្សេងទៀត ដូចជាកុមារ មនុស្សចាស់ ជនពិការ និងជនជាតិដើមភាគតិច តាមរយៈវិធានការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ស្ត្រីក្នុងកិច្ចពិគ្រោះយោបល់លើគោលនយោបាយ ការដឹកនាំ ការបង្កើតរបរចិញ្ចឹមជីវិត "ការអភិវឌ្ឍន៍បៃតង" និងការបង្កើនសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងសហគមន៍។

ផែនការសកម្មភាព ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ បានបង្កើតឡើងដោយមានគោលការណ៍ណែនាំពីក្រសួងបរិស្ថាន (MoE) និងការគាំទ្រពីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)។ ផ្អែកតាមកិច្ចពិគ្រោះយោបល់ក្នុងការរៀបចំផែនការយុទ្ធ

[34] ផែនការសកម្មភាពស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCAP/ឆ្នាំ ២០១៤-២០១៨) ក្រសួងកិច្ចការនារី GCCC/ឯកសារព្រាង ខែ មីនា ឆ្នាំ២០១៤

សាស្ត្រនារីរតនៈទី៤ ក្រសួងកិច្ចការនារី បានដាក់បញ្ចូលវិស័យជាយុទ្ធសាស្ត្រទី៦ ស្តីពី "យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតងនិងការគ្រប់គ្រងគ្រោះមហន្តរាយ" ឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។ យេនឌ័របានចាត់ទុកថាជាគោលការណ៍ណែនាំសំខាន់មួយ នៃការរៀបចំផែនការ និងការបង្កើតវិធានការនិងសកម្មភាព ស្តីពីការប្រែប្រួលអាកាសធាតុ។ ផែនការសកម្មភាពនេះនឹងត្រូវរៀបចំជាផែនការប្រចាំឆ្នាំ ដើម្បីអនុវត្តតាមរយៈថវិកាជាតិ និងដៃគូអភិវឌ្ឍន៍។

ផែនការសកម្មភាព ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ផ្អែកលើយុទ្ធសាស្ត្រដូចខាងក្រោម៖

១) ពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួលអន្តរវិស័យដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី ក្រុមស្ត្រីងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

២) បង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹង ស្តីពីយេនឌ័រ និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងភាពបន្សាំ

៣) លើកកម្ពស់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើយេនឌ័រជាមូលដ្ឋាន។

## អនុសាសន៍សម្រាប់គោលនយោបាយ៖

| | |
|---|---|
| បង្កើតក្របខណ្ឌគោលនយោបាយ និងកម្មវិធី ស្តីពីកសិកម្មសរីរាង្គ និងមាននិរន្តរភាព។ កម្មវិធីសេវាផ្សព្វផ្សាយកសិកម្ម គួរផ្តោតលើកសិករជាស្ត្រី ជាពិសេសក្រុមស្ត្រីងាយរងគ្រោះឱ្យបានខ្លាំងក្លា។ | ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ<br>ក្រសួងកិច្ចការនារី |
| សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ និងផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មសរីរាង្គ បន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុដល់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះ។ | ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| បង្កើនការយល់ដឹងដល់សហគ្រិនជាស្ត្រី អំពីការអភិវឌ្ឍន៍បៃតង តាមរយៈការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបច្ចេកវិទ្យាបៃតង និងលើកកម្ពស់សហគ្រិនភាព។ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| លើកកម្ពស់សកម្មភាពសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច រួមទាំងបច្ចេកវិទ្យាថ្មីៗដល់ស្ត្រីនិងក្រុមស្ត្រីងាយរងគ្រោះ តាមរយៈកសិកម្ម និងឧស្សាហកម្មធុនស្រាល "បៃតង "។ | ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍បៃតង |
| ជំរុញ និងលើកកម្ពស់សមភាពយេនឌ័រក្នុងយុទ្ធនាការអភិរក្ស និងគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ដើម្បីស្រូបយកឧស្ម័នកាបូនិច តាមសហគមន៍ ជាពិសេសសហគមន៍ជនជាតិដើមភាគតិច ។ | ក្រសួងកិច្ចការនារី<br>ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |

| | |
|---|---|
| សហគ្រិនស្ត្រី មានឱកាសដោយស្មើភាព ក្នុងការទទួលបានព័ត៌មានដេញថ្លៃសាធារណៈសម្រាប់លទ្ធកម្មផលិតផល និងសេវាបៃតង ជាពិសេសចំណីអាហារ (សរីរាង្គ និងមិនមានជាតិគីមី) ដែលផលិតឡើងដោយមាននិរន្តរភាព និងផលិតផលផ្សេងទៀតសម្រាប់ការិយាល័យរាជរដ្ឋាភិបាល សាលារៀន មន្ទីរពេទ្យ និងស្ថានទូត។ | ក្រសួងកិច្ចការនារី<br>ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| លើកកម្ពស់ភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈ (PPP) ដែលជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការលើកកម្ពស់ "ការអភិវឌ្ឍន៍បៃតង" និងសហគ្រិនភាពដល់ស្ត្រី។ ជាចាំបាច់គួរមានការកែសម្រួលក្របខណ្ឌគតិយុត្ត និងត្រូវមានការស្រាវជ្រាវបន្ថែមទៀត ដើម្បីកំណត់ឱកាសសមស្រប។ | ក្រសួងកិច្ចការនារី<br>ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គណៈកម្មាធិការគ្រប់គ្រងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| បង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព នូវប្រព័ន្ធផ្តល់ព័ត៌មានព្រមានទុកជាមុនឱ្យទាន់ពេលវេលា រួមទាំងការព្យាករណ៍អាកាសធាតុ ជាពិសេសដល់ស្ត្រីនៅតាមជនបទ និងក្រុមស្ត្រីងាយរងគ្រោះ។ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ប្រើប្រាស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី (WDCs) របស់ក្រសួងកិច្ចការនារីដើម្បីបង្កើនសមត្ថភាពយល់ដឹង ស្តីពីការបន្ស៊ាំនិងវិធានការកាត់បន្ថយនៃការប្រែប្រួលអាកាសធាតុសម្រាប់ស្ត្រី និងក្រុមស្ត្រីងាយរងគ្រោះ។ | ក្រសួងកិច្ចការនារី |

| | |
|---|---|
| សិក្សា ចងក្រង និងជំរុញឱ្យមានការប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់គ្រួសារ និងសហគមន៍ ជាពិសេសដល់ស្ត្រី ដូចជាថាមពលព្រះអាទិត្យ ខ្យល់ ជីវម៉ាស ជីវឧស្ម័ន ព្រមទាំងបច្ចេកវិទ្យាថ្មីៗ។ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| សិក្សាឱកាសសម្រាប់ការប្រើប្រាស់ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា (ICT) ស្ត្រីក្នុងវិស័យកសិកម្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍសហគ្រាសខ្នាតមីក្រូ តូច និងមធ្យមបៃតង និងទទួលព័ត៌មានផ្សេងៗទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ | ក្រសួងកិច្ចការនារី<br>ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ប៉ាន់ប្រមាណ និងសិក្សាស្រាវជ្រាវដើម្បីវាយតម្លៃភាពងាយរងគ្រោះ និងបង្កើនគុណភាពសេវាសុខភាពដល់ស្ត្រី ក្រុមស្ត្រីងាយរងគ្រោះនិងកុមារដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ដើម្បីធានាថាបញ្ហាសុខភាពស្ត្រី ក្រុមស្ត្រីងាយរងគ្រោះ និងកុមារ ឆ្លើយតបក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| បញ្ជ្រាបយេនឌ័រ និងអនុវត្តផែនការទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំងផែនការត្រៀមបង្ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ជាពិសេសគ្រោះទឹកជំនន់រាំងស្ងួត និងខ្យល់ព្យុះ។ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>គ.ជ.អ.ប |

| | |
|---|---|
| គួរបង្កើតយន្តការផ្តល់ព័ត៌មានត្រឡប់ពីសហគមន៍រងគ្រោះនៅពេលមានគ្រោះមហន្តរាយ។ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| បញ្ជ្រាបយេនឌ័រក្នុងដំណើរការរៀបចំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ សកម្មភាព និងកញ្ចប់ថវិកាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ ដើម្បីជានាតម្លាភាព និងគណនេយ្យភាព។ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ<br>គ.ជ.អ.ប |
| វិភាជន៍ថវិកាជាតិ ដើម្បីគាំទ្រការអនុវត្តន៍គោលនយោបាយ និងផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ដើម្បីជានានិរន្តរភាព។ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| បង្កើតក្របខ័ណ្ឌតាមដាន និងវាយតំលៃទៅលើយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ |

# សេចក្ដីថ្លែងអំណរគុណ

ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាត្រូវបានចងក្រងឡើងនៅក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រនិងរួមចំណែកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រសួងកិច្ចការនារីសូមថ្លែងអំណរគុណ ជូនចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការរៀបចំ ឯកសារនេះ ដូចតទៅ៖

**ក្រុមការងាររៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា** ទទួលខុសត្រូវលើដំណើរការ រៀបចំឯកសារទាំងមូល ក្រោមការដឹកនាំរបស់ លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្រុមការងារមានលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ ជាប្រធាន និងគាំទ្របច្ចេកទេសដោយផ្ទាល់ពីលោកជំទាវ កេត សំអាត ទីប្រឹក្សាជាន់ខ្ពស់ ក្រសួងកិច្ចការនារី លោកជំទាវ គឹម ស៊ីផាត់ អគ្គនាយិកា ក្រសួងកិច្ចការនារី និង លោក ថេ ឈុនហាក់អគ្គនាយករងក្រសួងកិច្ចការនារីលោកស្រី ញាណ សុចិត្រា ប្រធាននាយកដ្ឋាន សមភាពយេនឌ័រ លោកស្រី តែ វួចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងសមាជិក ផ្សេងៗទៀតមកពីនាយកដ្ឋានបច្ចេកទេសនានាចំណុះក្រសួងកិច្ចការនារី។ ក្រុមការងារមាន ការគាំទ្រផ្នែកបច្ចេកទេសពីគម្រោង **ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ** (PGEIII) ដែលមាន លោកស្រី Mia Hyun ជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំក្រសួងកិច្ចការនារី ជាអ្នកសម្របសម្រួល ទូទៅ គាំទ្រដោយក្រុមអ្នកជំនាញតាមវិស័យរបស់គម្រោង រួមមាន លោកស្រី ឌី ម៉ានី លោក ប៉ែន បូរី លោកស្រី ហេង សិលទិ លោក ឈន ថាវរិទ្ធី និង លោក គឹម សុពណ៌។ **ក្រុមការងារបច្ចេកទេសយេនឌ័រ** (TWG-G) បានផ្ដល់ជាវេទិកាដ៏សំខាន់ក្នុងការពិគ្រោះ យោបល់ជាមួយអ្នកពាក់ព័ន្ធ និងក្រុមអ្នកជួយកែសម្រួល (peer reviewers) ដែលជាអ្នក ជំនាញមកពីក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល បានជួយ ពិនិត្យ ឡើងវិញលើសេចក្ដីព្រាងតាមជំនាញពាក់ព័ន្ធ។ បច្ចេកទេសទាក់ទងនឹងរូបភាព ការរចនា និងសម្ភារៈសម្រាប់ផ្សព្វផ្សាយផ្ដល់ដោយ Good Morning Beautiful ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី១០៖** ជំពូកនេះដឹកនាំរៀបចំដោយ លោកជំទាវ ស៊ីវណ្ណ បុទុម រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងចងក្រងសេចក្ដីព្រាងដោយ លោក Udo Gartner កែសម្រួលដោយ លោកស្រី ជុត លាងវណ្ណី អគ្គនាយិកាក្រសួងកិច្ចការនារី លោកស្រី ចេង ជិនណេត អនុប្រធាននាយកដ្ឋានសមភាពយេនឌ័រ លោក សៅ ចាន់តូម៉ាលី លោក សុខ ពិសិទ្ធ លោកស្រី គឹម សុខ័ណ្ឌរី និង លោក ឈន ថាវរិទ្ធី។

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh